គម្រូនៃពាក្យបណ្ដឹង (សំណុំរឿង 3 )

# ពាក្យបណ្ដឹង

(ការសរសេរអំពីភាគីនៃបណ្ដឹងជាដើម ៖ សង្ខេប)

ទី១ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១.បង្គាប់ឲ្យចុងចម្លើយ Y បង់ប្រាក់ចំនួន ១000 ដុល្លារ និង បង់ការប្រាក់នេះ ៥% ក្នុងមួយឆ្នាំ ដោយគិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃដែលបានបញ្ជូនពាក្យបណ្ដឹងរហូតដល់ថ្ងៃសងរួច។

២.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ Y ។

និងទាមទារឲ្យតុលាការចេញសាលក្រម និង ប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន។

ទី២ មូលហេតុនៃការទាមទារ

១. នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧ រវាងដើមចោទ X និង ចុងចម្លើយ Y ដែលជាមេធាវី បានចុះកិច្ចសន្យាអាណត្តិដូចខាងក្រោម (ភ.១ ៖ លិខិតកិច្ចសន្យាអាណត្តិ) ៖

កម្មវត្ថុនៃអាណត្តិ ៖ កិច្ចការទាំងស្រុងដែលទាក់ទងនឹងការទាមទារឲ្យប្រគល់ប្រាក់កម្ចីរបស់ X ទៅកាន់ A

ប្រាក់សេវាមេធាវី ៖ ប្រាក់បង់ជាមុន ចំនួន ១000ដុល្លារ

ប្រាក់សេវាចំពោះភាពជោគជ័យ ចំនួន ១0% នៃផលប្រយោជន៍ដែល X បានទទួលនៅក្នុងរឿងក្ដីនេះ

២.នៅថ្ងៃដដែល ដើមចោទបានបង់ប្រាក់ជាមុនសម្រាប់សេវាមេធាវីចំនួន១000ដុល្លារ ផ្អែកតាមកិច្ចសន្យាអាណត្តិនៃរឿងក្ដីនេះ (ភ.២ ៖ ក្រដាសវិក្កយបត្រ)។

៣.ប៉ុន្តែ ចុងចម្លើយមិនបានអើពើនឹងការចាត់ការរឿងក្ដីដែលដើមចោទបានពឹងពាក់ទេ ហើយមិនបានចចារជាមួយ A ជាដើម។

៤.ដើមចោទយកពាក្យបណ្ដឹងនៃរឿងក្ដីនេះទៅកាន់ចុងចម្លើយ ហើយបង្ហាញឆន្ទៈថា នឹងរំលាយកិច្ចសន្យាអាណត្តិនៃរឿងក្ដីនេះ។

៥.ហេតុនេះ ដើមចោទទាមទារឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១000ដុល្លារដែលជាការឲ្យធ្វើបដិទានឡើងវិញនូវប្រាក់ដែលបានបង់រួច ដោយផ្អែកតាមការរំលាយកិច្ចសន្យាអាណត្តិនៃរឿងក្ដីនេះ និង បង់ការប្រាក់នេះ៥% ក្នុង១ឆ្នាំ ដូចដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ដោយគិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃដែលបានបញ្ជូនពាក្យបណ្ដឹងរហូតដល់សងរួច។

ភស្តុតាង

១.ភស្តុតាង លេខ ភ.១ លិខិតកិច្ចសន្យាអាណត្តិ

២.ភស្តុតាង លេខ ភ.២ ក្រដាសវិក្កយបត្រ

ឯកសារភ្ជាប់មកជាមួយ

១.ច្បាប់ចម្លងដើមនៃពាក្យបណ្តឹង ១ច្បាប់

២.ភស្តុតាង លេខ ភ.១ និង ភ.២ (ច្បាប់ចម្លង) ១មុខ ១ ច្បាប់

៣.កិច្ចសន្យាអាណត្តិក្នុងការធ្វើបណ្តឹង ១ច្បាប់

# ឯកសារចម្លើយ

(ការសរសេរអំពីភាគីនៃបណ្ដឹងជាដើម ៖ សង្ខេប)

ទី១ ការឆ្លើយតបចំពោះខ្លឹមសារដែលដើមចោទទាមទារឲ្យតុលាការចេញ

១.ច្រានចោទការទាមទារគ្រប់ចំណុចរបស់ដើមចោទ X។

២.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ X ។

ទី២ ទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះមូលហេតុនៃការទាមទារ

១.ទទួលស្គាល់មូលហេតុនៃការទាមទារ ១ ទាំងស្រុង។

២.ទទួលស្គាល់មូលហេតុនៃការទាមទារ ២ ទាំងស្រុង។

៣.មិនទទួលស្គាល់មូលហេតុនៃការទាមទារ ៣ ។ បន្ទាប់ពីបានទទួលអាណត្តិនៃរឿងក្ដីនេះពីដើមចោទ ចុងចម្លើយបានចចារបន្ថែមជាមួយ A និងបានទាមទារឲ្យសងប្រាក់កម្ចី (ត.១ ៖ លិខិតទាមទារ)។

៤.ទទួលស្គាល់មូលហេតុនៃការទាមទារ ៤ ទាំងស្រុង។

៥.មានវិវាទចំពោះមូលហេតុនៃការទាមទារ ៥ ។

ទី៣ ការតវ៉ា-ការទូទាត់

ដូចដែលបានលើកឡើងខាងលើ ចាប់ពីពេលដែលបានទទួលអាណត្តិនៃរឿងក្ដីនេះពីដើមចោទមក ចុងចម្លើយបានចចារបន្ថែមជាមួយ A និង បានទាមទារឲ្យសងប្រាក់កម្ចី។ ហេតុនេះ សេវាមេធាវី និង ការចំណាយនោះបានកើតឡើង។

សេវាមេធាវីដែលចុងចម្លើយយកគឺ៤00ដុល្លារ និង ការចំណាយដែលត្រូវបានទទួលស្គាល់ថាមានភាពចាំបាច់សម្រាប់ឲ្យចុងចម្លើយចាត់ការរឿងក្ដីនេះ គឺ១00ដុល្លារ សរុបចូលគ្នាគឺ ចំនួន ៥00ដុល្លារ (ត.២ ៖ លិខិតគណនាទឹកប្រាក់)។

ផ្អែកតាមការលើកឡើងខាងលើនេះ ចុងចម្លើយមានសិទ្ធិទាមទារកម្រៃដែលស្មើនឹង៤00ដុល្លារ ព្រមទាំងសិទ្ធិទាមទារឲ្យសងសោហ៊ុយស្មើនឹង១00ដុល្លារ។

ចុងចម្លើយមានសិទ្ធិទាមទារកម្រៃ និង សិទ្ធិទាមទារឲ្យសងសោហ៊ុយដូចបានលើកឡើងខាងលើចំពោះដើមចោទ ហើយបានបង្ហាញឆន្ទៈថា ធ្វើការទូទាត់នូវចំនួនទឹកប្រាក់ទាំងនេះទៅនឹងសិទ្ធិលើបំណុលនៃការទាមទាររបស់ដើមចោទនៅក្នុងរឿងក្ដីនេះ ។

ទី៤ សរុប

ដូចដែលបានលើកឡើងខាងលើ ការទាមទាររបស់ដើមចោទមិនមានមូលហេតុឡើយ។

ភស្តុតាង

១.ភស្តុតាង លេខ ត.១ លិខិតទាមទារ

២.ភស្តុតាង លេខ ត.២ លិខិតគណនាទឹកប្រាក់

ឯកសារភ្ជាប់មកជាមួយ

១.ភស្តុតាង លេខ ត.១ ដល់ ត.២ (ច្បាប់ចម្លង) ១ច្បាប់

២.កិច្ចសន្យាអាណត្តិក្នុងការធ្វើបណ្តឹង ១ច្បាប់

គម្រូនៃឯកសារត្រៀម (សំណុំរឿង 3 )

# ឯកសារត្រៀមលើកទី១

(ការសរសេរអំពីភាគីនៃបណ្ដឹងជាដើមៈ សង្ខេប)

ទី១ អំពីមូលហេតុនៃការរំលាយ

ការរំលាយកិច្ចសន្យាដែលដើមចោទអះអាង គឺជាការរំលាយដែលផ្អែកតាមក្រមរដ្ឋប្បវេណី មាត្រា ៦៤៧ (ការរំលាយកិច្ចសន្យាអាណត្តិ) ដូច្នេះហើយ ចំពោះកិច្ចសន្យាអាណត្តិ គូភាគីអាចរំលាយកិច្ចសន្យាពេលណាក៏បាន ទោះបីជាមិនមានមូលហេតុសមរម្យក៏ដោយ។

ទី២ អំពីការតវ៉ាចំពោះការទូទាត់

មិនទទួលស្គាល់ការចរចារដែលចុងចម្លើយបានធ្វើឡើងជាមួយ A ឡើយ។

ចាប់ពីពេលដែលបានអាណត្តិក្នុងរឿងក្ដីនេះ រហូតដល់ពេលដែលបានទទួលលិខិតជូនដំណឹងស្ដីពីការរំលាយកិច្ចសន្យារបស់ដើមចោទ ចុងចម្លើយមិនបានធ្វើកិច្ចការអាណត្តិរបស់ខ្លួនទាល់តែសោះ (ភ.៣ ៖ លិខិតស្ដីពីសេចក្ដីថ្លែងការណ៍របស់ A )។

ដូចនេះ ដោយសារតែចុងចម្លើយមិនមានសិទ្ធិលើបំណុលលើសោហ៊ុយ និង សិទ្ធិទាមទារឲ្យសងការចំណាយជាអាទិ៍ចំពោះដើមចោទទេ ហេតុនេះ តុលាការមិនទទួលស្គាល់ការតវ៉ាអំពីការទូទាត់ឡើយ។

សូមអរគុណ